**៣.-សម្រេកជីវិត-សម្រិតគម្លាន**

- ស្រឡាញ់ខ្លួនឱ្យស្ងួនចំណី
- ស្រឡាញ់ទឹកដីឱ្យប្រណីទឹកចិត្ត
- ស្រឡាញ់ជីវិតឱ្យប្រព្រឹត្តទាន សីល សមាធិ និងបញ្ញា

ដោយប្រណម្យ យ៉ាងប្រណីត ដ៏ស្និតស្នាញ ។

៙៙៙

## ផ្កាឈូករ័ត្ន

៙

*ឆ្នាំ១៩៥៦-៥៧ ខ្ញុំជាសិស្ស ថ្នាក់ទី៥ នៅអនុវិទ្យាល័យ ព្រះមុនីវង្ស ។ ខ្ញុំបានបងកើ្មម្នាក់ ឈ្មោះ គៀងចន់ ។ វាមានឪពុកជាខ្មែរព្រះត្រពាំង ម្ដាយវាមានឈាមជ័រជាយួន ។ អាចន់ មានបងប្រុសម្នាក់ ឈ្មោះ គោត និងប្អូនស្រីម្នាក់ ឈ្មោះ គិមច ។ ផ្ទះវានៅឯភូមិកាប់ទេះ ក្នុងឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ។*

*បានអាចន់ជាកើ្ម ខ្ញុំបាត់អផ្សុកគ្រាន់បើ ។ ធ្វើឱ្យខ្ញុំរីករាយក្នុងជីវិត ត្បិតវាចេះនិយាយរឿងគួរឱ្យសប្បាយ រីករាយ ។ វានិយាយពីនេះពីនោះ ពុំចេះអស់ពាក្យទេ ។ ពាក្យថាខ្មែរព្រះត្រពាំង ត្រូវតាំងលំនៅ នៅក្នុងរង្វង់ខ្មែរកម្ពុជាក្រោមដែរ ។*

*ខ្ញុំមានមិត្តខ្មែរក្រោម ម្ដងនេះគឺជាប្រុស ពុំមែនជាស្រី ដូចពេលមុនទេ ។ យើងយកគ្នាជាសំឡាញ់ ម្ដងនេះ ពិតជាមិនពេញប្រាសទេ ។ យើងទាំងពីរសុទ្ធតែ ចូលក្នុងវ័យ កំពុងពេញពាល ។*

*អាចន់ ជាកូនសិស្សអនុវិទ្យាល័យ ពឹងពាក់អាស្រ័យដោយវត្តកំផែង នៅកុដិដើមខ្នុរ ។ អាចន់មានប្រាជ្ញាជាងបងគោត ដែលនៅកុដិជាមួយគ្នា ។*

*រៀងរាល់ល្ងាច ខ្ញុំតែងតែ ជិះកង់លំហែរ យកខ្យល់អាកាស ជាមួយអាចន់ នៅតាមមាត់ស្ទឹងសង្កែ និងនៅតាមទីផ្សារ រួចក៏វិលទៅសំរាក នៅលើខឿនចេតិយមុខ*

វត្តកំផែង ៗ នៅទីនោះ យើងជជែកគ្នាលេង ពីនេះ ពីនោះ ពុំចេះអស់រឿង ជាពិសេស រឿងចោរលួចចិត្ត គឺរឿងលួចស្រឡាញ់ស្រី ក្នុងពេលយុវវ័យនោះឯង ។

អាច៉ក់ប្រសប់ដឹកនាំរឿងណាស់ ។ វាធ្វើអត្ថាធិប្បាយ ថានាងនេះស្អាត នាងនោះល្អ ៗ ហើយវាសួរខ្ញុំថា ឯងស្រឡាញ់នាងណា ? ខ្ញុំអេះអុញ មិនដឹងនឹងឆ្លើយនឹងវាថា យ៉ាងណា? ព្រោះ តាំងតែពីនាងឈារេត ទៅរៀនឯភ្នំពេញ ចោលខ្ញុំទៅ ខ្ញុំលែងមាន បំណងអ្វីទាំងអស់ទៅនារី ទោះបីជាស្អាត ឬក៏ល្អយ៉ាងណា ក៏ដោយ ។ តែ ដល់វាជន្ទញយៗ ធ្វើម្តេច មិនដោយតាម ព្រោះបេះដូងរបស់ខ្ញុំ ធ្លាប់មានស្នាម ជិតជាម ដោយ ការខ្វាយខ្វល់ !

អាច៉ក់វាយល់ចិត្តខ្ញុំណាស់ ព្រោះកាលដែលយើងទាំងពីរនាក់ ជិះកង់ធ្វេលផ្សារ បានឃើញ ទេពធីតាល្អឯក កំពុងមើលសៀវភៅបណ្តើរ លក់ដូរសៀវភៅបណ្តើរ ។ នាងនោះ មានឈ្មោះពិរោះនាមថា **កុឡាបសាលីរ័ត្ន** ។ នាង **កុឡាបសាលីរ័ត្ន** ត្រូវបានខ្ញុំ កំណត់ ទុកក្នុងដួងចិត្តថា ជា **ផ្កាឈូករ័ត្ន** ។ ពុំមែនមានតែរូបសម្បត្តិទេ ព្រមទាំងនាងមាន ចរិយា សម្បត្តិ វិជ្ជាសម្បត្តិ និងភោគសម្បត្តិថែមទៀត ។ នាងជាចៅស្រីសំណព្វលោកថៅកែ អ៊ាម និងយាយទិព្វ ។ បើនិយាយ ពីថៅកែប្តីប្រពន្ធនេះ ឪពុក ម្តាយខ្ញុំ គាត់ស្គាល់ ច្បាស់ណាស់ ព្រោះផ្ទះគាត់ នៅជិតវត្តសង្កែក្បែរផ្ទះខ្ញុំដែរ ហើយឪពុកខ្ញុំ ក៏ធ្លាប់ធ្វើជា អ្នកត្រួតលើគូលីវាយ ថ្ម នៅភ្នំសំពៅឲ្យគាត់ទៀត ។ ខ្ញុំយល់ ថា ជាការ បង់មៀ្យត ទៀតហើយ មិនកើតទេក្នុងរឿងស្នេហានេះ តែអាង៉ក់ វាជជេស មុខរឹងទទឹងទិស ធ្វើ យ៉ាងម៉េច ឲ្យខ្ញុំ តែខ្ញុំជ្រើសរើសផ្លូវត្រូវ ខាងលួចស្នេហ៍នាង **ផ្កាឈូករ័ត្ន** ទាល់តែខ្ញុំភ្លាត់ភ្លាំង ស្មារតី គិតអ្វីលែងយល់ ។

ដែលវាខំអន្ទងខ្ញុំ ឲ្យចូលក្នុងអន្ទាក់ ស្នេហ៍យ៉ាងនេះ ព្រោះវាក៏ត្រូវ រងកម្មទ្រាំលួច ស្រឡាញ់ ឧត្តមដួងចិត្តរបស់វាដែរ ដែលជាបុត្រី លោកចៅហ្វាយស្រុកផង ។ យីអាង៉ក់ នេះ ពិតជាធ្វើមធំ ហ៊ានលួចស្រឡាញ់ កូនស្រីលោកចៅហ្វាយស្រុកផង ។ រីឯថ្លើមខ្ញុំ ពិតជាពាសមេឃ ព្រោះហ៊ានលួចជ្រែកពពក ស្វែងរកចាប់ដួងចន្ទ្រា ។ សំឡាញ់ទាំង ពីរ តើអ្នកណា ខិលជាងអ្នកណា?

ការលួចស្រឡាញ់កូនស្រីគេ បំពេអារម្មណ៍ យ៉ាងសែន រំភើប រំជើប រំជួល ស្រួល ស្រើប ញាប់ញ័រ ដោយតម្រេកតណ្ហា ។ មិត្តទាំងពីរ គ្មាននរណា ឃាត់នរណា មានតែពន្យុះថែម ។

ឃើញខ្ញុំនិងអាចិត ប៉ប៉ាច់ ប៉ប៉ោច សើចសប្បាយ ក្អាកក្អាយ ក៏ផ្អើលដល់កូនសិស្សលោកផ្សេងទៀត ដែលធ្លៀតចូល មករួមចំណែក ក្នុងការ ជជែកលេងដែរ ។ ពេលនោះ បងតោក គាត់បង់មកបន្ទូរ បរិយាកាស ពីការតប់ប្រមល់ ទាល់គំនិត ខ្វល់ក្នុងដួងចិត្ត ត្បិតគាត់ រមែងលាក់គំនិត ពីចិត្តទាក់ទងរវាងសិស្សនារី ដែលមកពីអូរដំបង ផ្សេងរកចំណេះវិជ្ជា ជួនក៏បានជួបគូព្រេង វង្វេងវាសនា ដែលសម្ញុំសិក្សានៅកុដិដើមខ្នុរ ។

តោក លូកសម្ដី ៖

- អាពីរនាក់ មានអ្វីប្លែក បានជាបែកពពុះមាត់ដូចជាឆ្កែឆ្កួត?
-អើ គ្នាជាឆ្កែឆ្កួត ឯងជាឆ្កែជា កុំមកជិតគ្នាវើយ!
-អញថាលែងទេ បើឯងមានរឿងអ្វីល្អ គួរតែបែកឲ្យគ្នាបានស្ដាប់ផង! ( តោក អង្វរ ) ។

មានគ្នាបីនាក់ យើងប្ដូរសាច់រឿង ។ បន្តិចមកមានអ្នកចំណូលថ្មី មួយទៀត គឺជាកូនសិស្សលោក នៅកុដិដើមខ្នុរ ដដែល ខ្ញុំភ្លេចឈ្មោះ វាឈឹង ។

អាឃ្លុច! ឯងថ្ងៃនេះ ម្ដេចក៏សប្បាយប្លែកម៉េះ?

(តោក ហៅឈ្មោះខ្ញុំ ថា អាឃ្លូច ខ្ញុំក៏មិនថាអី កុំឲ្យតែវាហៅខ្ញុំថា "អាចាដូចអាត់" ទើបខ្ញុំខឹង ។ ព្រោះថា ចាជូវគឺជាបបរផ្អែមធ្វើដោយអង្ករដំណើបសលាយសណ្ដែក សៀងស្ករនិងទឹកខ្ទិះដូង ។ ចាជូវ ជាបង្អែម ឡែមៗ ដ៏មានឱជារស យ៉ាងស្រស់មាត់ ប្រាកដជាឆ្ងាញ់ពិសា ពិតជាស្នាដៃ លើកតម្លៃ ស្រីយួន ដែលចេះក្បួនផ្សេផ្សំ ដ៏ប៉ិនប្រសប់ ។

អាត់ គឺពាក្យសម្ដីដែលសំដែងចេញពីយួន និយាយខ្មែរ មិនច្បាស់ ចង់ប្រើប្រាស សំដៅលើពាក្យ អាចម៍នោះឯង ។

បើប្រសិនជា ចាជូវ ត្រូវ ក្លាយជា អាចម៍ ឬក៏ធុំ ដោយក្លិន លាមក តើនឹងមាននរណាហ៊ាន? ទៅហ៊ានភ្លក្ស ក្រៅពីពួកគម្រក់ អាក្រក់ដូចជា ពពួកត្មាត ក្អែក រុយ មមង់ ដែល ជាពពួកគម្រង់សត្វ ស្វាត់ស្វះស្វែង ប្រឡែងលេង តែទៅលើអំពើ កខ្វក់ យ៉ាង អាក្រក់អាក្រី !

បើគេយោងទៅតាមផ្លូវធម៌ បើកុំតែបានពពួកតម្រង់សត្វ ប្រឹងទប់ស្កាត់ ការរាយប៉ាយ យ៉ាងអនាធិបតេយ្យ ដោយសារលាមក កក់ជ្រាំ សម្រាមសម្រាស់ កាកសំណល់ ប្របល់ប្របូក ស្មោគគ្រោក គគ្រុក ពុករលួយ ស្អុយរលេះ ប្រេះហើមស្ពឹង ប្រផេងប្រផាង ដំណាំឲ្យគ្រប់សាកសព កុំអីយើងនឹងវិនាសអន្តរាយ ដោយជំងឺជង្កាត់ ព្រោះអត់អនាម័យ ។

នៅស្រុកបារាំង និងប្រទេសជឿនលឿនក្នុងលោក កុំតែមានពួកអ្នកកើបសម្រាម ដែលអ្នកផងរមែងមើលងាយ មើលថោកថាជាជនស្មោគគ្រោកក្នុងការប្រឡូកលូកប្រមូលបញ្ចូលធុង ប្រុងប្រោសសំអាត កុំអីមេក្រិមិនឹងនាំភាពអប្រិយ មកក្រញីក្បាលគ្រប់ៗគ្នា ព្រោះហេតុថាការខ្វះការអនាម័យ ។

ម្យ៉ាងទៀត ដែលនាំឲ្យខ្ញុំ គ្រាន់តែគេថាចាដូវ អាត់ តែប៉ុណ្ណោះ? ព្រោះនឹងនាំឲ្យខ្ញុំនឹកដល់ ស្រីយួនដែលដួតដួនអង្គុយលក់ចាដូវ បញ្ចេញតល់ភ្លៅ យ៉ាងសស្អាប តើមានបុរសណាខ្លះ មិនព្រឺរោម រួចទ្រោមរិទ្ធិ នៅក្រោមអំណាចស្រូបព្រលឹងរបស់នាង? មានតែអ្នកដែលមានជីវិតស្លាប់ទេ ដែលមិនចេះខឹង មិនប្រឹងកំរើក រំពើក! អ្នកដែលនៅរស់ដ៏មានព្រលឹង ពិតជាខឹង ទោះបីគេរឹង ក៏ដូចជាខ្ញុំប្រឹងរស់ ព្រោះចង់សុំចូលប្រឡងរិទ្ធិ និងគេដែរ ។)

ខ្ញុំញញឹម ហើយឆ្លើយតបទៅតោក៖

-ឯង ទើបតែភ្ញាក់ពីដេកស្រមៃ? ឬក៏ទើបតែបញ្ចប់សំបុត្រ ផ្ញើទៅ "កញ្ញាសូឡិចខ្មៅ" ទេដឹង?

-ពុ ខ្ញុំនិយាយដូច្នេះ បែបត្រូវ ទើបតោកបង្វែងជានថា គ្នាទើបតែមកពីពួនស្តាប់ពួកឯងពិភាក្សាគ្នាទេតើ!

-អើ! បើឯងដឹងរឿងគ្នាហើយ ម្តេចចាំសួរ? (ខ្ញុំសម្រួលសម្តី)។

ក្លាមនោះ រឿងស្នេហា ឬ រឿងលួចកាច់ផ្កាពីសំណាក់ក្មេងវត្ត និងក្មេងផ្ទះ ក៏រូតរះ បរិយាយជាហូរហែ តំប៉ែលត រអឺលដូចទឹកហូរ ហាក់មិនចេះនឿយហត់ លុះត្រាតែដល់កំណត់អធ្រាត្រ ទើបបែកគ្នា យ្វាយ្វាតរៀងៗខ្លួន ទៅកាន់ទីដំណេក ដោយត្រឹកស្មែក ត្រូវទៅរៀនផង ។

មេរៀន ក៏ពុំដែលបានទន្ទេញ តើនឹងឲ្យខ្ញុំបានចាំម្តេចមិញ បើរវល់តែទៅរ៉ៃរឿងលួចស្រឡាញ់ស្រីៗ នៅពេលលោកគ្រូបើកបញ្ជីហៅឈ្មោះរកសិស្សឲ្យទៅសូត្រមេរៀនម្តងៗ ខ្ញុំភ័យចង់សន្លប់ ខំបន់ឲ្យតែលោកគ្រូចុចចំឈ្មោះសិស្សណាក៏ចំចុះ ប៉ុន្តែកុំឲ្យតែចុចចំឈ្មោះខ្ញុំ ។ កាលពីនៅថ្នាក់ទាប មិនទាន់មានស្នេហាចូលលុក ខ្ញុំបន់ឲ្យតែលោកគ្រូចុចចំឈ្មោះខ្ញុំ ខ្ញុំនឹងអាលបញ្ចេញការបេះចាំឲ្យលោកគ្រូស្តាប់ ព្រមទាំងចង់បង្អួតសិស្សដទៃផង ។

ថ្ងៃមួយ អាង៉ក់ វារហាក់រហន់មករកខ្ញុំ ហើយហើបមាត់ថា "ខូចការហើយអាសួគី!" ។

ខ្ញុំសួរវាថា យ៉ាងម៉េចទៅហើយ?

វាឆ្លើយថា វាបែកការណ៍ ។

-វាបែកការណ៍រឿងអី? (ខ្ញុំសួរបញ្ជាក់) ។

នាងកូនលោកចៅហ្វាយស្រុក នាងយកសំបុត្រដែលអញផ្ញើទៅនាង ទៅឲ្យឪពុកម្តាយនាង ។ មើលទៅអញអស់ផ្លូវដើរហើយ !

ខ្ញុំក៏ថាបណ្តោយ "ឱស្វាអស់ឈើលោតហើយតើ!"

តាំងពីថ្ងៃនោះ អាង៉ក់ វាបេះតែធ្វើមុខស្រពោន ដើរឈ្ងោកដី លែងនិយាយស្តីព្រោកប្រាជ្ញដូចសព្វមួយដង ។ វាប្រាប់ខ្ញុំថា វាសុំលាខ្ញុំ ទៅឆ្ងាយហើយ រួចវាបានផ្តែផ្តាំខ្ញុំថា កុំខ្ញុំឲ្យធ្វើដូចវា !

ខ្ញុំក៏ទទួលរួមចំណែកទុក្ខជាមួយក្មេខ្ញុំ ដោយក្រៀមក្រំក្នុងចិត្ត ព្រោះវាជាជីវិតមួយថ្មីមួយ!

ណាមួយលទ្ធផល ជាបន្តបន្ទាប់នៃការប្រឡងត្រីមាសលើកទី១ ពិន្ទុរបស់ខ្ញុំបេះតែខ្សោយទៅៗ ។ ទាំងវិជ្ជាខាងបកប្រែពីភាសាពីខ្មែរទៅបារាំង និងពីបារាំងមកខ្មែរ ទាំងសរសេរតាមសូត្រជាភាសាបារាំង ទាំងតែងសេចក្តីបារាំង ក៏ខ្ញុំធ្លាក់ពិន្ទុពីមធ្យម ។ បានជាប់តែខាងសរសេរតាមសូត្រខ្មែរមួយគត់ រហូតដល់លើស៩ពិន្ទុផងក្នុងចំណោមវិជ្ជាទាំង៩មុខនេះ ។ បូកសរុបខ្ញុំត្រូវខ្វះ១០ពិន្ទុ ។

ខ្ញុំអស់សង្ឃឹម ហើយគិតក្នុងចិត្តថា នៅដំណាច់ឆ្នាំនេះ នឹងបានវិលត្រឡប់ទៅជួយទៅជួយធ្វើស្រែចម្ការឪពុកម្តាយវិញហើយ !

ថ្ងៃដែល ខ្ញុំកំពុងតែវិលវល់ លោកគ្រូបារាំងខាងគណិតសស្ត្រ ត្រូវប្រកាសលទ្ធផលពីចំណោទ ។ លោកគ្រូចាប់ចែកឲ្យកិច្ចការសិស្ស រៀងៗខ្លួន លុះត្រាតែចប់អស់ នៅចន្លោះតែខ្ញុំមួយ ជាហេតុធ្វើឲ្យខ្ញុំព្រួយជាពន់ប្រមាណ ទើបលោកគ្រូបានប្រកាសជាចុងក្រោយ ហើយនិងឲ្យសិស្សទាំងអស់យកតម្រាប់តាម គឺខ្ញុំត្រូវបានជាប់លេខ១ ក្នុងពិន្ទុ ១៧/២០ ហើយត្រូវគុនជាទ្វេផង ។ ក្រោយពីបានទទួលលទ្ធផល ជាទីគាប់ចិត្តនេះ ខ្ញុំសប្បាយដូចហោះ ខ្ញុំសប្បាយ ដូចបានឡើងឋានសួគ៌ទាំងរស់ ។

តើលទ្ធផលនេះ មកពីព្រេងវាសនា ប្រាជ្ញា បុណ្យមានពីកំណើត ឬ ក៏មកពីការខិតខំរៀនសូត្ររបស់ខ្ញុំ?

សរុបពិន្ទុ មកដល់ថ្ងៃនេះ ខ្ញុំបានលើស៤ពិន្ទុ ។

ចាប់ពីថ្ងៃនេះទៅ ខ្ញុំឈប់រវើរវាយទៀតហើយ ខ្ញុំខំទន្ទេញមេរៀន លុះត្រាតែចាំស្ទាត់ គ្មានចន្លោះត្រង់ណាមួយ ហើយខ្ញុំបានទទួលលទ្ធផលលេខ១ ស្ទើរតែទាំងអស់ រហូតដល់ មេសូត្ររត់មាត់ បារាំង ក៏សឹងចាំទល់សព្វថ្ងៃ ។

ដល់ចុងឆ្នាំ ខ្ញុំត្រូវ មានឡើងថ្នាក់ជាស្ថាពរ ។

## ផ្កាក្រទាន់អូរជីបខ

## ឬ

## កញ្ញាសូឡិចខ្មៅ

បានជាឲ្យឈ្មោះថាកញ្ញាសូឡិចខ្មៅ ព្រោះនាងនោះ បានជិះសូឡិចខ្មៅ ទៅរៀនជារាល់ថ្ងៃ ។ សូឡិចជាទោចក្រយាន មានម៉ាស៊ិន ដូចម៉ូតូដែរ តែកម្លាំងខ្សោយជាងម៉ូតូ ឬម៉ូបីឡែត ។ ជាធម្មតា សូឡិច តែងមានពណ៌ខ្មៅ បើខ្ញុំហៅថាសូឡិចខ្មៅ ពិតមានការផ្ទួនពាក្យ ហើយ ដែលបារាំង គេហាមដាច់ខាតក្នុងការសរសេរ ព្រោះវាខាតឥតអំពើ តែខ្មែរយើងខ្លះ ជាពិសេស ចំពោះខ្ញុំដូចជា មិនជាទើសទាល់ទេ វារឹតតែលើកកម្រិតពាក្យរឹតតែឲ្យច្បាស់ឡើង ។

នៅជំនាន់នោះ កូនសិស្សដែលទៅរៀន ហើយជិះសូឡិប មានតែមួយគត់ នៅក្នុងខេត្តបាត់ដំបង បណ្ដាលឲ្យនាងសូឡិបខ្មៅ រឹតតែពិសេសជាងគេ ជាងឯង ហើយរមែងមានការយកចិត្តទុកដាក់ ក្នុងការតយតន់ពីសំណាក់ យុវសិស្សទាំងឡាយ ជាពិសេស គៀងតោក សំឡាញ់ខ្ញុំតែម្ដង (ខ្ញុំបងក្មេ ទាំងបងទាំងប្អូន)។

នាងមានឈ្មោះហៅថា កញ្ញា ម៉ុនសារ៉ាន់ ជាកូនមេឃុំ អូរដំបង ឈ្មោះ ដា ។

ថ្វីត្បិតតែមិនមានប្រាជ្ញា ជាងប្អូន ក្នុងការរៀនសូត្រ តែតោក មានប្រាជ្ញា ជាងអាច៉ត់ឆ្ងាយណាស់ក្នុងការស្នេហា ព្រោះថាវាអាចជ្រើសគូសង្សារ ឲ្យសមនឹងមាឌ ឲ្យសមនឹងឋានៈ មិនបាក់មុខបាក់មាត់ ទោះបីឪពុករបស់សង្សារ មានបុណ្យស័ក្តិតូចជាងឪពុករបស់ឧត្តមស្នេហារបស់អាច៉ត់មែន តែតោកវាបាន សំរេចផល លុះត្រាចប់ចុងចប់ដើម មិនដូចអាង៉ក់ ដែលរវល់តែដង្ហក់ប្រកាច់ចាប់មិនឈ្នះ ព្រោះវាដាំដើមក្រានមិនប្រមាណផ្ទាំង ។

កញ្ញាសូឡិបខ្មៅ ត្រូវព្រួញកាមទេព របស់តោក បាញ់ខ្ទេចខ្ទាំញាំញី នឹងប្រឹងសំភិរៀនសូត្រទៅទៀត ក៏មិនកើត ក៏ប្រឹងដំទើតរកមុខរបរ ដើម្បីចិញ្ចឹមជីវិតអាត្មា និងសង្សារ របស់ខ្លួន ។ ហេតុនេះហើយ បានជា នាងប្រឹងដាក់ពាក្យប្រឡងចូល ធ្វើជាគិលានុបដ្ឋាយិកា នៅគ្រាបន្ទាប់ ដោយពុំទាន់បានជាប់សញ្ញាប័ត្រមធ្យមសិក្សា(Diplôme d'études secondaires ) ផង ។

តែនាងបានសំរេច តាមសេចក្ដីប្រាថ្នា ក្នុងឆាកជីវិតរបស់នាង ទោះនៅក្នុងរបបសីហនុ ក៏ដូចជានៅក្នុងរបបលន់ណុល និងរបបខ្មែរក្រហមដែរ ។

សព្វថ្ងៃនាងបានភៀសខ្លួនទៅដល់ សហរដ្ឋអាមេរិក ជាមួយគ្រួសារ និងកូនប្រាំនាក់ គឺ ១.នាយកុមារ ២.នាងមុំធំ ៣.នាយធីត ៤. នាយម៉ៅ ៥.នាងមុំតូច ព្រមទាំងម្ដាយក្មេកចាស់ ។

កូននាងទាំងបួន មានគូស្រករអស់ទៅហើយ នៅឡើយតែអាទី៣ គឺ អាធីតប្រុ អា ធី-ត ដែលកម្រនឹងជាប់អន្ទាក់ស្នេហា ព្រោះវាបេះការដើងអុកណាស់ ។ ថ្ងៃមួយខ្ញុំទៅលេងតោក និងសារ៉ាន់ ព្រមទាំង ក្មេងៗ ឯសហរដ្ឋ ដោយខ្ញុំចង់ពត់វា បញ្ចូលគន្លងបង្គងបង្កបង្កើតជីវិត តែចិត្តវារឹងរូសណាស់ វាក្រឡាស់នឹមមួយរំពេច ។ ឪពុកម្ដាយវា

ក៏ទាល់តម្រិះ ដោយ មិនចេះរកវិធីណា ឲ្យកូនបានឡើង ទៅកៀងទា ឯឋានសួគ៌ គ្រាន់នឹងបន្តពូជពង្សវង្សត្រកូល ។

**ផ្កាប្រទាលផ្ញើប្រាណ**

**ឬ**

**យកពងមាន់**

**ទៅផ្ញើនឹងក្អែកស**

ផ្គរលាន់ឯបូរស្នូរកណ្តុក
អ្នកតាចាស់ស្រុកឱបដៃយំ
កំពិសឡើងលើកំពូលភ្នំ
ក្អែកសសម្ងំក្នុងគុម្ពត្រែង ។

ឥន្ទ្រទំនាយ

ចូលដល់ថ្នាក់ទី៤ អាង៉ក់ បានសុំទៅរៀន ឯខេត្តកំពង់ឆ្នាំង ព្រោះវាមានការខ្មាសអៀននឹងកូនស្រីលោកចៅហ្វាយស្រុក ។

មុនវាទៅរៀន ឯខេត្តកំពង់ឆ្នាំង វាបានស្នើ ខ្ញុំ ឲ្យជួយនិយាយអង្វរ បងស្រីខ្ញុំ ដែលចេះវិជ្ជាកាត់ដេរខោអាវ យ៉ាងស្ទាត់ជំនាញ បង្ហាត់បង្រៀន នាងគិមង៉ ដែលត្រូវជាប្អូនស្រីវា ។ នាងមានអាយុ១៣ឆ្នាំហើយ ។ នាងរៀនអក្សរ បានតិចតួច ។ នាងត្រូវការ ចេះរៀនកាត់ដេរ នឹងគេ ។ បំពោះ នាងដែលមានឪពុកម្តាយ សម្បូណ៌ហូរហៀរទៅដោយសម្បត្តិ ទោះមិនចាំបាច់ធ្វើអី ក៏អាចចិញ្ចឹមខ្លួនរស់ដែរ ។

បងស្រីខ្ញុំ ក៏សុខចិត្តទទួលនាងជាកូនសិស្ស ព្រោះ គាត់ស្រឡាញ់ខ្ញុំណាស់ ហើយកាលនោះគាត់ត្រូវបែកពីប្តី ដែលមានសញ្ជាតិ ជាយួនចិត្តឃោរឃៅ រត់ចោលគាត់ទៅ ដោយបន្សល់នូវកូនប្រុសពីរ ឈ្មោះ អាឌុឌនិងអាថារ កំព្រាឪពុក ។

បងស្រីខ្ញុំ ខំដេរខោអាវផង បង្រៀននាងគិមង៉ផង និងដណ្តាំបាយ ឲ្យយើងទាំងអស់គ្នាញ៉ាំផង ។ ក្រោមដំបូលផ្ទះស្បូវដ៏តូចនេះ មានបងស្រីខ្ញុំនិងកូនពីរនាក់ នាងគិម

ង៉ អាមុតនិងខ្ញុំក្រោយ មកមាន គង់សេន មកសុំស្នាក់នៅបន្ថែមទៀត ។ ពិតមែន តែផ្ទះចង្អៀត តែចិត្តយើងឥតមានចង្អៀតចង្អល់ទេ ។

ព្រះត្រៃរត្ន លោកបានទស្សទាយថា អំណើះតទៅត្រូវមាន ក្អែកស សម្ងំក្នុងគុម្ពត្រែង ។

រីឯចំណងជើងខាងលើ ដែលស្នាក់ស្នើរ យកគុណនាម "ស" ដាក់បន្ថែមលើពាក្យក្អែក។ នេះជាការចម្លែកណាស់ ! ដើម្បីឱ្យអស់លោកអ្នកអានបានជ្រាបច្បាស់ សូមលោកអ្នកមេត្តាអានរឿងព្រេងសំដែងដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលមានទាក់ទងពីរឿងក្អែកស ដូចតទៅ៖

## រឿងព្រេងទាក់ទងនឹង
## ពិធីបណ្ដែតប្រទីប
## សំពះព្រះខែ និងអកអំបុក

ជាទំនៀមរៀងមក អ្នកស្រុកក្នុងប្រទេសកម្ពុជាទាំងមូល តែងធ្វើពិធីបណ្ដែតប្រទីប នៅវេលារាត្រីបវរណាចេញវស្សា (បុរិមវស្សា) គឺនៅថ្ងៃពេញបូណ៌មីខែអស្សុជ រាល់ឆ្នាំ ប៉ុន្តែនៅរដ្ឋធានីភ្នំពេញ ព្រះរាជាតែងប្រារព្ធធ្វើពិធីនេះ រួមជាមួយនឹងពិធីអុំទូក សំពះព្រះខែ និងអកអំបុក ដែលរាប់បញ្ចូលក្នុងពិធីទ្វារទសមាសមួយសំរាប់រដ្ឋ គឺធ្វើនៅថ្ងៃ១៤-១៥កើត និង១រោជខែកត្តិក រាល់ឆ្នាំ ដូចដែលយើងបានដឹងមកស្រាប់ ។ ពិធីបុណ្យប្រពៃណីទាំងឡាយ ដែលគេប្រារព្ធធ្វើ នៅក្នុងស្រុកនិមួយៗសុទ្ធសឹងមាន ហេតុផលទាក់ទងនឹងរឿងដំណាល ។ ចំពោះ ពិធីបណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុកនេះ ក៏មានរឿងដំណាលពីបុរាណមកដែរ ដូចតទៅ៖

## រឿងបណ្ដែតប្រទីប

៨៨៨

ក្នុងកាលពីព្រេងនាយ នាខាងដើមនៃភទ្ទកប្បយើងនេះ មានសត្វក្អែកស ញី-ឈ្មោល បានកាប់សំបុកពង នៅនឹងឈើមួយដើម ដែលដុះនៅឆ្នេរសមុទ្រហើយបាន បញ្ចេញពង តាមធម្មតាជាតិសត្វនោះចំនួន៥ ។ ថ្ងៃមួយ ជាទេសកាល បណ្ដាលឲ្យមាន ភ្លៀងព្យុះបោកបក់ កួចយកសំបុក បក្សីព្រមទាំងពងឲ្យធ្លាក់ចុះទៅក្នុងទឹកកំពុងហូរ ។

លុះពេលល្ងាច ក្អែកញី ឈ្មោលហើរត្រឡប់មកពីរកចំណីអាហារវិញ ស្រាប់តែ បាត់សំបុក ព្រមទាំងពង ហើយ ឃើញស្នាមរប៉ាត់រប៉ាយអាចឲ្យយល់បានថា “ ពិតជា ការណ៍អន្តរាយ បណ្ដាលអំពីខ្យល់ព្យុះ” ។ ប៉ុន្តែ ក្អែកស ញីឈ្មោលនោះ នៅមិនអស់ ចិត្ត បេះតែសញ្ជប់សញ្ជឹងគិតក្រែងដូច្នេះ ដូច្នោះ ក៏វិយោគបោកប្រាណ ព្រោះនឹក ស្ដាយ ស្រណោះពងទាល់តែស្លាប់ទាំងគូទៅហើយទៅកើតជាព្រះឥន្ទ្រាធិរាជ នៅនា ត្រៃត្រឹង្ស សួគ៌ទេវលោក ។

និយាយអំពីពងក្អែកទាំង៥ ដែលធ្លាក់ទៅក្នុងទឹក ហើយត្រូវខ្សែទឹកហូរនាំយកទៅ នោះ ក៏ធ្លាក់នៅក្នុងកណ្ដាប់ដៃនៃសត្វមាន់ ស្ដេចនាគ អណ្ដើក គោ និងខ្លា ដែលរើស បានមួយៗម្នាក់ យកទៅបីបាច់រក្សានៅទីអាស្រ័យរៀងៗខ្លួន។ ពងនោះ លុះដល់កំណត់ ពេលនឹងញាស់ហើយ ស្រាប់តែកើតកូនចេញមក សុទ្ធតែជាមនុស្សប្រុសទាំង៥ ។ ឯសត្វជាអាណាព្យាបាលឃើញសេចក្ដីអស្ចារ្យពេក ក៏ខំថែរក្សា ចិញ្ចឹមដោយយកចិត្ត ទុកដាក់ ជាទីបំផុត ។

លុះទារកទាំង៥នោះ មានវ័យវឌ្ឍនាការធំឡើង ក៏មាន ចិត្តគិតរៀងខ្លួនថា “ ខ្លួនអញជាមនុស្សសោះ ចុះហេតុអ្វីបានជាមាតាបិតា សុទ្ធតែជាសត្វតិរច្ឆាន ដូច្នេះ ! ” គិតសព្វគ្រប់ហើយ ទើបរកមធ្យោបាយរៀងៗខ្លួនលា បិតាមាតាចិញ្ចឹមទីទៃៗ របស់ខ្លួន ដើម្បីស្វែងរក រៀនសិល្ប វិជ្ជា សន្សំកុសលកសាងពុទ្ធភូមិ រៀងៗខ្លួន ។ សត្វជា អាណាព្យាបាលទាំង៥ មានបណ្ដាំតែមួយដូចគ្នាថា “ បើកូនចេញទៅធ្វើការកសាងពុទ្ធ

ភូមិបានសំរេច នៅថ្ងៃណា វេលាណា យើងសូម ផ្ញើ ឈ្មោះរបស់យើង ឲ្យ នៅ ជាប់នឹង ឈ្មោះអ្នកផង! ” ។

ព្រោះហេតុនោះឯង បានជាក្នុងភទ្ទកប្បយើងនេះ មាន ព្រះ ពុទ្ធ ៥ ព្រះ អង្គ ទ្រង់ ព្រះនាមថា កកុសន្ធោ (មាន់) កោនាគមនោ(នាគ) កស្សបោ(អណ្តើក) គោតមោ(គោ) សិរីអារ្យ មេត្តេយ្យោ(ខ្លា) ដែលបានត្រាស់ តាមលំដាប់បងប្អូន និងបារមី ហើយ យក នាមសត្វទាំង៥ ដែលជា អ្នក ចិញ្ចឹម មកប្រកបភ្ជាប់ នឹងព្រះនាម ព្រះអង្គ តាមបណ្តាំ ក្នុង រឿងតំណាលដូចពោល ហើយនេះ ។

មាណពទាំង៥ កាល បេញ បាក ប៉ាន មាតាបិតា ចិញ្ចឹម រៀងខ្លួន មក ក៏បាន ជួបគ្នា ទាំង៥នាក់ នៅ កន្លែងមួយ លុះសាកសួរ គ្នា ទៅ ឃើញថា មានគំនិត ព្រមទាំងហេតុភេទ ដូចគ្នា ក៏សុំគ្នាធ្វើជា បងប្អូន រួមរស់ជាមួយគ្នា រហូតតទៅ ។

ថ្ងៃមួយ នៅ វេលាដែល មាណពទាំង៥ កំពុងតែជជែក គ្នា រកមាតាបិតា ដើមនោះ ព្រះឥន្ទ្រព្រមទាំងអគ្គមហេសី ដែលជាមាតាបិតា ដើម ក៏និម្មិតខ្លួន ជាក្អែកស ញីឈ្មោល ហើរ មកទុំលើមែកឈើជិតនោះ ហើយសាសព្ទប្រាប់ មណព ទាំង៥ ឲ្យជឿប្រាកដ ថា “ ខ្លួននេះ ឯង ហើយ ជា មាតាបិតា ដើម ” ។ មាណពទាំង៥ ក៏ លុតជង្គង់ ថ្វាយ បង្គំ ចំពោះ បុព្វបុរស ទាំងពីរ ដែងសេចក្តី ស្តាយ ចំពោះការ មិន បាន ទៅ នៅ បំរើ ឪពុកម្តាយ នោះ ព្រោះក្អែកស ទាំងគូ មិន អនុញ្ញាតឲ្យ ទៅនៅ ជាមួយទេ គ្រាន់តែផ្តាំថា “ បើកូនរាល់គ្នា រលឹក អាល័យយើងណាស់ ហើយ ចង់ បូជា អ្វីដល់ យើង ទាំងពីរ នាក់ ចូរកូន គូស ខ្សែ ជើងក្អែក នៅគ្រប់វត្ថុ ដែលជាសំណែននោះ ហើយឧទ្ទិសឲ្យ យើងទៅ អំពើនេះ មុខ ជា នឹងបានផ្សាយផលដល់យើងមិន ខាន ឡើយ ” ថាតែប៉ុណ្ណោះ ក៏អន្តរធាន បាត់ទៅ ។

មាណពទាំង៥ បានចាំបណ្តាំហើយ ក៏នាំគ្នាទៅរក រៀនសិល្បវិជ្ជា បួសជាតាបស បំរើនព្រ័តក្នុងព្រៃ ខាងក្រោយមក ក៏នាំគ្នា ធ្វើបុណ្យសុន្ទរ៍ទាន រំលឹកគុណ តាមបណ្តាំ នោះ ជាជរាប ព្រមទាំងគូស ខ្សែ ជើង ក្អែក នៅ លើ វត្ថុ ជា សំណែន សែន រួច បណ្តែត តាមខ្សែទឹកទៅ ដើម្បីបូជា ក្អែកស ញី ឈ្មោល រហូតជាប់ ជា ទំនៀមទម្លាប់ មកដល់ សព្វថ្ងៃនេះ ។

ប៉ុន្តែតាមមតិអ្នកស្រុកខ្លះសំអាងថា“ គេធ្វើពិធីបណ្តែតប្រទីបនេះ ដើម្បីឧទ្ទិសបូជាដល់ស្នាមព្រះពុទ្ធបាទ និងព្រះចន្ទមកែវ ដែលប្រតិស្ឋាននៅនាពិភពនាគ ” ។

រួមសេចក្តីទៅឃើញថា ទោះបីអាចារ្យដែលពោលថា “ការធ្វើពិធីនេះ ដើម្បីឧទ្ទិសបូជា ដល់ស្នាមព្រះពុទ្ធបាទ ក្តី ដល់ព្រះចន្ទមកែវក្តី ដល់ក្អែកសញ្ញីឈ្មោលក្តី ឬថាដល់ព្រះបុល្លាមណីចេតិយក្តី” ក៏សុទ្ធសឹងតែមានហេតុផលល្អចំពោះពុទ្ធសាសនាដូចគ្នា គឺមានសេចក្តីស្របគ្នាច្រើន មិនមានជាទំនាស់ប៉ុន្មានទេ ។ ឯគម្ពីររតនសង្គ្រោះក្តី សាស្ត្រាក្អែកសក្តី គម្ពីរពុទ្ធវង្សក្តី ពុំមានបង្គាប់ថា ឲ្យធ្វើបុណ្យយ៉ាងនេះយ៉ាងនោះឡើយ ប៉ុន្តែអាស្រ័យរឿងរ៉ាវទាំងឡាយនេះបុរាណាចារ្យ បេះតែផ្សំថែមធ្វើមករហូតទាល់តែជាប់ជាទំនៀមទំលាប់ដល់សព្វថ្ងៃ។

ខ្ញុំសុំចុះផ្សាយបន្ថែមនូវរឿងសំពះព្រះខែនិងអកអំបុក ក៏ប៉ុន្តែពុំត្រូវចាត់ទុកជាការជំនួយគាំទ្រគំនិតលំអក្អែកសទេ - គ្រាន់តែបន្តភ្ជាប់ដើម្បីបង្រួបសេចក្តី ដែលបានផ្តួចផ្តើមអភិប្រាយរួចមកហើយ តែប៉ុណ្ណោះ!

**រឿងសំពះព្រះខែ និងអកអំបុក**

មានដំណាលថា ក្នុងកាលពីព្រេងនាយ កាលព្រះបរមគ្រូនៃយើងទាំងឡាយ ត្រាច់រង្គាត់អន្ទោលជាតិ ក្នុងវដ្តសង្សារ នៅឡើយនោះ ក្នុងជាតិមួយ ព្រះអង្គទ្រង់យោនយកកំណើតជាសត្វទន្សាយ ។ នៅរាល់ថ្ងៃពេញបូណ៌មី ទន្សាយពោធិសត្វតែងសមាទានរក្សាឧបោសថសីល ដោយឧទ្ទិសជីវិតព្រះអង្គជាទានបរមត្ថបារមី ដើម្បីបំពេញព្រះពោធិសម្ភារឲ្យបានត្រាស់ដឹងជាព្រះពុទ្ធ ។ នៅថ្ងៃពេញបូណ៌មីមួយព្រះឥន្ទ្រទ្រង់ជ្រាបក៏កាឡាខ្លួនជាព្រាហ្មណ៍ចាស់ មកសុំសាច់ព្រះអង្គជាអាហារ ។ ព្រះពោធិសត្វសុខចិត្តបូជាជីវិតដើម្បីឲ្យសាច់ដល់ព្រាហ្មណ៍ចាស់ ប៉ុន្តែព្រាហ្មណ៍ចាស់ ទូលព្រះអង្គថា “ខ្លួនគាត់ កាន់សីលមកយូរហើយ មិនអាចនឹងសម្លាប់សត្វបានទេ” ទើបទន្សាយ

ពោធិសត្វ បង្គាប់ឲ្យព្រាហ្មណ៍ចាស់ បង្កាត់ភ្លើងឡើង រួចក៏លោតចូលសម្លាប់ខ្លួន ដើម្បីឲ្យបានសាច់ដល់ព្រាហ្មណ៍បរិភោគ ។ ប៉ុន្តែ មុននឹងលោតចូល ទៅក្នុងភ្នក់ភ្លើងនោះ ព្រះអង្គ ទ្រង់អធិដ្ឋានថា សុំឲ្យព្រះឆាយាលក្ខណ៍នៃព្រះអង្គ ទៅប្រតិស្ឋានផ្តិតជាប់នៅនិងមណ្ឌលព្រះចន្ទ រហូតលុះទីបំផុតកប្ប ដោយអានុភាពនៃទានមរមត្ថបារមីនោះ ។

អាស្រ័យរឿងនេះទើបបាន ជារូបទន្សាយ មានប្រាកដនឹងមណ្ឌលព្រះចន្ទ ដូចដែលយើងមើលឃើញសព្វថ្ងៃនេះ ។

លុះចំណេរមកខាងក្រោយ បណ្តាជននាំគ្នារលឹកកំណើតទន្សាយ ពោធិសត្វនេះ ទើបធ្វើពិធីបុណ្យ ដែលហៅថា “ អកអំបុក សំពះព្រះខែ” គឺសំពះព្រះឆាយាលក្ខណ៍ព្រះពោធិសត្វនោះឯង ដោយនាំគ្នាជ្រើសរើស ចំណី អាហារ ជាទីគាប់ចិត្ត តំរូវនឹងអធ្យាស្រ័យនៃសត្វទន្សាយ មាន “ ចេក អំបុក ដំឡូង ដូងត្រាវ ” ជាដើម យកមកឧទ្ទិសថ្វាយផង ជាហូរហែ ជាប់ជាទំនៀមទំលាប់ មក រហូតដល់សព្វថ្ងៃនេះ ។

អ្នកស្រុក បានជាប្រារព្ធ ធ្វើពិធីសំពះព្រះខែ អកអំបុក នៅថ្ងៃពេញបូណ៌មី ខែកត្តិកនេះ ព្រោះពេលដំណាច់ខែវស្សាកាលផង ជាពេលសំបូរដោយចេក អំបុក អំពៅ ត្រាវ ដំឡូងផង ។៚

នាងគិមឆ៊ ប្រកបដោយសម្បុរស ដូចពងមាន់បក ។ ក្នុងការចំរើនវ័យបានមួយថ្ងៃ នាងល្អមួយកម្រិត ប្រៀបបានទៅនឹងផ្កាប្រទាលផ្ញើប្រាណ ។ នាងខំផ្ចិតផ្ចង់រៀនដេរមិនឈប់ដៃ ដើម្បីឲ្យបានចេះឆាប់ និងអាលវិលត្រឡប់ទៅកាន់លំនៅឋានរបស់នាងវិញ ដោយបាននាំយកនូវចំណេះដឹងទៅផង ។

បងខ្ញុំ ខំបង្រៀននាង ដោយ យកចិត្តទុកដាក់ នឹងមិនយកថ្លៃឈ្នួលទេ ហើយក៏មិនប្រើឲ្យនាងធ្វើការអ្វីក្រៅពីរៀនដេរដែរ ។ តែនាងនៅមិនស្ងៀម ចេះតែចង់ជួយធ្វើនេះធ្វើនោះ ជាពិសេសជួយមើលក្មួយវុធ និងក្មួយថា ។

នាងមានប្រាជ្ញាខាងរៀនដេរឆាប់ចេះណាស់ ។ ជាហេតុធ្វើឲ្យ ទាំងបងស្រីខ្ញុំ ទាំងឪពុកម្តាយនាង ទាំងបងប្រុសនាងទាំងពីរ ព្រមទាំងខ្ញុំសប្បាយចិត្ត ឥតឧបមា ។

នៅពេលជូននាងទៅលេងផ្ទះនាងម្ដងៗ ឪពុកម្ដាយនាង ទាំងបងប្រុសនាង ទទួលបងស្រីខ្ញុំ និងខ្ញុំ ដោយរាក់ទាក់ និងអរគុណជាពន្លឹក ។

នៅពេលត្រឡប់មកបាត់ដំបងវិញ ក៏មានបេកជូនដំឡូង ស្វាយ អង្ករ ត្រីងៀត ត្រីឆ្អើ ពងមាន់ពងទា ផ្អកប្រហុក និងបន្លែបន្លុក ផ្សេងៗ យកមកជាមួយផង ។

នៅភូមិកាប់រទេះត្រង់គីឡូម៉ែត្រលេខ២៦១ ឪពុកម្ដាយនាងគិមង៉ មានដីស្រែមួយកន្លែង លាតសន្ធឹង តាមបណ្ដោយថ្នល់ជាតិលេខ៥ ភ្ជាប់ពីទីរួមខេត្តបាត់ដំបងទៅកាន់ក្រុងភ្នំពេញ ខាងស្ដាំដៃ បណ្ដោយប្រហែលមួយគីឡូម៉ែត្រ ទទឹងប្រហែល៤០០ម៉ែត្រ។ នៅលើដីទួល បួនជ្រុងទ្រវែង២០០គុណ១០០ម៉ែត្រ មានសំណង់ឈើមួយប្រក់ក្បឿង សង់ខ្ពស់ពីដី ព័ទ្ធព័ន្ធទៅដោយដើមឫស្សីប្រួងប្រាង ជាជំណាងកំពែងពាំងរារាំងចោរខ្មួយ។ នៅលើវាលស្មៅ ខាងក្រោយផ្ទះ ក៏ត្រូវខ័ណ្ឌ ដោយដើមឫស្សីដែរ គឺជាវាលសំរាប់សត្វគោក្របី រស់នៅ ។

នៅស្របនឹងគល់ឫស្សី មានប្រឡាយទឹក ដក់ជាប់ជានិច្ច ទោះនៅរដូវប្រាំង ក៏ដូចជានៅរដូវវស្សា ។ ជាហេតុបណ្ដាលឲ្យការស្រោចស្រព ដំណាំ មានគ្រប់គ្រាន់គ្រប់រដូវ ព្រោះដោយសារ នយោបាយទឹកបរិបូណ៌ ។

មាន់ ទា ក៏ត្រូវបានចិញ្ចឹម ឲ្យមាន ចំណី ចំណុក និងទឹកឲ្យហែលលេង តាមចំណូលចិត្តសត្វ ។

ព្រលិត លំចង់ ក៏ដុះស្លឹក រីកផ្ការហង់ នៅលើប្រឡង់ប្រឡាយ រីករាយទៅដោយហ្វូងមច្ឆាជាតិ ។

នៅលើដើមស្វាយដ៏ត្រសាយត្រសុំ ក៏មានសត្វ លលក កុកកំប្រុក ក្រសារ មកប្រាថ្នាពឹងដែរ ជាហូរហែ រហូតអស់ទាំងសត្វ ។

ឆ្កែឆ្មា រក្សាសម្បត្តិ ក៏មានការប្រុងប្រយ័ត្ន ចាំយាម ហាមប្រាម មិនឲ្យចោរចេញចូល ប្រមូលលួច របស់របរ គោក្របី ។

នៅខាងជើងផ្ទះ ជង្រុកស្រូវ មួយ ធំជ្រងោ ជំបូលប្រក់សង្កសី ពួនប្រចបដើមឫស្សី បំពេញផ្ទៃដោយស្រូវដ៏បរិបូណ៌ ។

ភូមិឋានដ៏ប្រឡឹងនេះ ត្រូវបានរៀបចំ យ៉ាងវិសេសវិសាល ដោយទឹកដៃនៃ ជនជាតិខ្មែរព្រះត្រពាំង សំរាំងបេញមកអំពីកម្ពុជាក្រោម។

នាងគិមធ័ ជាបុត្រី សំណព្វតែមួយ ម៉្លោះហើយ នាងចង់បានអ្វី ក៏ឪពុកម្ដាយបំពេញចិត្តដែរ ។

បងស្រីខ្ញុំ ក្មួយប្រុសខ្ញុំ ប្អូនប្រុសខ្ញុំ និងខ្ញុំ ក៏ត្រូវបានស្រស់មាត់ក្នុងការបំប៉នខ្លួន ស្ងួនម្ហូបចំណី ដោយសារនាងខ្លះដែរ។

ថ្ងៃមួយ ខ្ញុំក៏ចង់ បង្ហាញនាង នូវលំនៅស្រុកចម្ការ របស់ ឪពុកម្ដាយ ខ្ញុំ ឯអូរស្រឡៅ ។ ទាំងបងស្រីខ្ញុំ ទាំងក្មួយប្រុសខ្ញុំ ទាំងខ្ញុំ ទាំងគិមង៉ ក៏ទៅកាន់ស្ថានីយរទេះភ្លើងបាត់ដំបង ក្នុងគោលបំណង ឆ្ពោះទៅកាន់វ៉ា អូរស្រឡៅ ។

ទៅដល់ភូមិ ឃើញដើមក្រូច ពោធិសាត់ ដែលឪពុកខ្ញុំដាំដុះជាជួរៗ ហើយមានផ្លែផ្កាក់ទាំងចង្កោមៗ នាងសប្បាយចិត្ត ណាស់ ព្រោះទើបតែនិងលើកទីមួយហើយ ដែលនាងបានឃើញយ៉ាងនេះ ។ នាងលូកដៃបេះ ពីដើមមួយទៅដើមមួយ ហាក់ដូចជាព្រួយ ប្រឹងរត់ប្រញាប់ ចង់ដណ្ដើមផ្លែ ខ្លាចក្រែងមានគេបេះមុនបាត់ ។

ឃើញនាង ជ្រួសជ្រុល វិសប៉ះបន្លាក្រូច ខ្ញុំក៏ស្រែកប្រាប់នាង ថាប្រយ័ត្ន ក្រែងលោវាមុតបន្លា !

នាងស្រែកតបមកខ្ញុំវិញថា នាងមានការប្រុងប្រយ័ត្នហើយ !

ក្រោយពីបាន រត់លេងសប្បាយតាមចម្ការ នាងខ្សឹបប្រាប់ខ្ញុំថា អូរស្រឡៅគួរឲ្យស្រឡាញ់មែន!

ចប់ការរៀនដេរបានស្ទាត់ជំនាញហើយ នាងគិមង៉ បានលា អ្នកដែលបានឲ្យចំណេះដល់នាង និងអ្នកដែលនាងធ្លាប់រាប់អាន ត្រឡប់ទៅកាន់លំនៅឋាន ឯភូមិកាប់រទេះវិញ ដោយនាងបានថតរូប ថត ជាមួយនឹងខ្ញុំ ទុកជាការរលឹកផង ឬក៏ជាចំណងអ្វីមួយ?

ឆ្នាំ១៩៩៧-៩៨ នៅថ្នាក់ទី៤ ខ្ញុំ បានដឹងខ្លួនថា ខ្ញុំ នៅខ្សោយ ខាងចំណោទ ព្រោះចំណោទនេះ ពុំដូចជា ចំណោទ សំរាប់គិតលេខ បូក សង គុន ចែក នៅថ្នាក់ទាបរហូត មកដល់ត្រីមាសទី១ នៃថ្នាក់ទី៩ឡើយៗ ចំណែកវិជ្ជាផ្សេងៗទៀត ក៏ប្លែកៗដែរ

ម៉្ងោះ ខ្ញុំត្រូវតែ ខំប្រឹងឲ្យមែនទែន ។ ដោយសារ ខ្ញុំធ្លាប់តែបណ្តែតបណ្តោយ ឲ្យពេលវេលាវិលចោលទៅទទេ អស់រយៈពេលជាយូរ ទើបខ្ញុំមានការលំបាក ស្តារបំណេះវិជ្ជា ឡើងវិញណាស់ ។ ខំខាងវិជ្ជានេះ ខ្វះខាងវិជ្ជានោះ តែខ្ញុំប្រឹងតែបណ្តុះវិជ្ជា គណិតសាស្ត្រឡើងវិញ ព្រោះខ្ញុំពុំធ្លាប់ដែលបាញ់គេសោះ បំពោះមុខវិជ្ជានេះ ។

លទ្ធបុនឆ្នាំនេះ ខ្ញុំបានឡើងថ្នាក់ ទាំងត្រដាបត្រដួស ព្រោះតែ រវល់ទៅខ្វល់ពីរឿងចង់លួចកាប់ ផ្កាកុឡាប បាត់ដំបង ដែលអន្ទងចិត្តខ្ញុំ ដោយ អាសំឡាញ់អាប់ !

**ចំប៉ាបាត់ដំបង**

ឱបាត់ដំបង បណ្តូលចិត្តអើយ!

ខ្ញុំសូមលាហើយ លាទាំងអាល័យ...

៙

ឆ្នាំ១៩៥៨-៥៩ ខ្ញុំរៀននៅថ្នាក់ទី៣ ដើម្បីប្រឡងយក សញ្ញាប័ត្រមធ្យមសិក្សានៅចុងឆ្នាំ ។

បងស្រីខ្ញុំ ត្រូវទៅរស់នៅ ជាមួយឪពុក ម្តាយខ្ញុំ ដែល កាលណោះ ឪពុកបង្កើតរបស់ខ្ញុំគាត់ធ្វើទាហាន មានឋានន្តរ ស័ក្តិ ជាពលបាលត្រី ត្រូវផ្លាស់ទៅនៅភូមិកូបនិម្មិតជិត ព្រំប្រទល់ដែនខ្មែរ-សៀម ។

ខ្ញុំថ្លែងពី **គង់សេន** សំឡាញ់ថ្មីរបស់ខ្ញុំ ។

កាលនៅវ័យកុមារ គង់សេនជាកូនកំព្រា ឪពុក ។ ម្តាយឈ្មោះហាយ កើតនៅស្រុកស្វាយទង។

បងស្រី **ហាយ** (ខ្ញុំហៅគាត់ថា បង) បានទាក់ទង នឹងបង **គង់ឡុច** យកធ្វើជាស្វាមីទីពីរ ។

ឆ្នាំ១៩៥៨ បង **គង់ឡុច** មានឋានន្តរស័ក្តិ ជាអនុសេនីយទោ ( ពាក់សក្តិពីរ ) តាំងទីបញ្ជាការ នៅបន្ទាយស្រុកសិរី សោភ័ណ។

ដោយសារ មាន ឪពុក ក្រៅ ខោ ជា នាយ ទាហាន គង់សេន វា ក្វាហាន ណាស់ ។ ណាមួយ វា មាន លុយ ចាយ ណា មួយ វា មាន អំណាច ណា មួយ រូប វា ក៏ សង្ហារ សម្បុរស ជ្រះថ្លា ប្រមុះ គោង ដូច បារាំង ប្រហែល ជា ឪពុក បង្កើត វា ជា ជនជាតិ បារាំង ទេ ដឹង?

ខ្ញុំ ធ្លាប់ ឮ បង គង់ឌួច ជំណាល ប្រាប់ ខ្ញុំ ថា ចៅហ្វាយ នាយ របស់ គាត់ ជា បារាំង ប្រហែល ជា គាត់ លួច ពង្រត់ បង ហាយ ពី បារាំង ផង ទំនង ដូច ជា មាប្រុប របស់ ខ្ញុំ កាល ណោះ គាត់ ជំរត់ មីង ខ្ញុំ ពី កណ្តាប់ ដៃ បារាំង ហើយ ក៏ តាំង មក លាក់ ខ្លួន ពួន សម្ងំ សុខ ឯ ភូមិ អូរស្រឡៅ ហើយ គាត់ រស់ នៅ ប្រែក ពី គេ ឯង ព្រោះ មាន តែ ផ្ទះ គាត់ ទេ ដែល មាន កា ហ្វេ ផឹក នៅ ជំនាន់ នោះ ។

បុង ឆ្នាំ ១៩៥៨ គង់សេន ជា ក្មេង របុិល រប៉ូច ណាស់ ។ វា បាន មាត់ បាន ក អ្នក ណា ក៏ ចូល ចិត្ត វា ដែរ ជា ពិសេស សិស្ស នារី ក្មេងៗ តែ ម្តង ។

ខ្ញុំ ស្គាល់ សេន ម្តង ណោះ ពុំ ដូច អាច៉ត់ ពី គ្រា មុន ទេ ។ តែ ខ្ញុំ ពុំ មែន បាន ស្វាយ ណាយ ក្រុប ឡើយ ។ ខ្ញុំ នៅ តែ ទាក់ទង ជាមួយ អាច៉ត់ និង គោករហូត គ្រាន់ តែ រយាល វេលា បន្តិច ព្រោះ ត្រូវ នៅ ឆ្ងាយ ពី គ្នា ។

សេន បាន ទាក់ទាញ ទឹកចិត្ត សិស្ស នារី ម្នាក់ ឈ្មោះ យ៉េន ដែល មក សុំ ផ្ទះ ឪពុក មា ម្តាយ មីង ឈ្មោះ ម៉ូ-រឿម ស្នាក់ នៅ ដើម្បី រៀន វិជ្ជា ។ ឪពុក ម្តាយ នាង ជា អ្នក ស្រុក មន្តលបុរី ភូមិ ឫស្សី ក្រោក ។ នាង សម មាន រហ័ស នាម ថា ជា ផ្កា ឫស្សី ក្រោក ដែល បាន បោក បញ្ឆោត ចិត្ត សេន ឲ្យ សែន ចម្បែង!

មាប៊ូ មីង រឿម បាន ទិញ ដី មួយ កំណាត់ ខាង មុខ របស់ ឪពុក ម្តាយ ខ្ញុំ ដើម្បី សង់ ផ្ទះ ឈើ ប្រក់ ក្បឿង មួយ យ៉ាង សែន ស្កឹម ស្កៃ ។ គាត់ មាន កូន ៦ នាក់ គឺ នាង ឈារី នាយ រ៉ាន់ឌី នាង ឈារិន នាយ រ៉ាន់នី នាង សៅរឿត នាយ ស៊ីរ៉ាត់ ។

ក្រោយ ពី សេន បាន កាប់ ផ្កា ឫស្សី ក្រោក ខ្ញុំ ក៏ បង់ លូក ក្តិប ផ្កា ចំប៉ា បាត់ ដំបង រឹត បំណង ស្នេហ៍ ជាមួយ នាង ឈារី ។ ក៏ ប៉ុន្តែ ខ្ញុំ ជា កម្លោះ កំសាក ញី នៅ ពេល នោះ ព្រោះ ខ្ញុំ នៅ តែ ញញៀត ញញៀម ច្រើន ជា ពិសេស ខ្ញុំ មិន ហ៊ាន ហៅ នាង ណារី ចំ ឈ្មោះ ឲ្យ ពិរោះ ភិរម្យ ឲ្យ សម តាម ពាក្យ ស្នេហា ថា អូន បាន ត្រឹម តែ ហៅ នាង ឈារី ថា អ្នក បង ដោយ បម្លង ពាក្យ តាម ប្អូនៗ នាង ទាំង អស់ ។

ខ្ញុំមានអាយុបងនាងប្រហែល បីបួនឆ្នាំ ចុះកម្មអ្វីខ្ញុំពុំហ៊ាន ហៅនាងថាអូន?

ធម្មតា កាលបើគេស្នេហាគ្នាហើយ គេតែងតែ លួកលួននឹងគ្នា ដោយប្រុសទោះបីអាយុតិចជាងស្រីក្តី ក៏ប្រុសមានសិទ្ធិ ហៅស្រីថាអូនដែរ!

ឆ្នាំ១៩៥៨-៥៩ ខ្ញុំបានឡើងថ្នាក់ទី ៣ ។ ឆ្នាំនេះ ខ្ញុំរៀនបណ្តើរ មានគូរសង្សារបណ្តើរ ដោយសារតែទទួលសំណើរបស់គង់សេន ដើម្បីបំបិទមាត់ខ្ញុំកុំឲ្យប្រណែននឹងវា ។

មាឌុំមានចម្ការក្រូច នៅភូមិបត់សាលា ចម្ងាយប្រមាណ ៨ គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង ។ ដោយសារចម្ការក្រូចនេះ ដែលមានទំហំ ប្រហែល ៤ ហិកតារ ឲ្យផលជាអតិបរមា ទើបគាត់បានសង់ផ្ទះ ឈើជម្កាល់លើអិដ្ឋទល់រត ប្រក់ក្បឿងក្រហមឆ្អិនឆ្អៅ ជាលំនៅដ៏ស្កុកស្កម្ភ ។

ថ្ងៃមួយ ខ្ញុំនិងសេន មានភ័ពវាសនា បឹងបានទៅលេងចម្ការក្រូច របស់នាងឆារី ដោយការបបួលអំពីនាយអ៊ាន់ឌី ហាក់បីដូចជាចង់ ដឹកញីបន្សុំឈ្មោល ។

ចម្ការក្រូចដ៏ធំល្វឹងល្វើយ ធ្វើឲ្យយើងខ្ញុំបានធូរស្បើយ ពីរឿងតប់ប្រមល់ខ្វល់ក្នុងការសិក្សា ។ ជាពិសេស បំពោះ ការបណ្តុះពន្លកស្នេហាឲ្យលាស់មែកបែកសន្លឹក នឹកញញឹមសង្សឹម ទុកជាមុខជា នឹងហុចផ្កាផ្លែ ជារៀងរាល់រដូវ ។

ម្តាយឪពុក នាងឆារី ហាក់ យល់ដល់ចិត្ត កម្លោះក្រមុំ ដែលប្រៀបបាន នឹងឃ្មុំនិយមផ្កា តាមក្តីប្រាថ្នា នៃសត្វ ។

ថ្ងៃនេះ ក្រោយពីបេះក្រូចពោធិសាត់ បានគ្រប់ចំនួនហើយ យើងក្មេងៗ ដែលកំពុងតែពេញនិយមក្នុងការ បំរើកាមតណ្ហា ត្រូវទទួលមុខងារថ្មី ប្រញាប់បេះប្រទ្បេះក្រូចឆ្មា ។

ក្រូចឆ្មាកំពុងតែបេះ ដៃក៏ប្រទ្បេះផ្លែក្រូចឆ្មា កប់គ្នាលេងប្រឡែងយ៉ាងស្និទ្ធស្នាល ត្រេកត្រអាលក្នុងកាមគុន ។

ថ្ងៃនេះយើងទាំងអស់គ្នាសប្បាយពុំអាចនឹងបរិយាយថ្លែងបាន។

ពេលល្ងាច វិលត្រឡប់ផ្ទះវិញ រទេះគោពោរពេញទៅ ដោយផ្លែក្រូចពោធិសាត់ និងក្រូចឆ្មា ។ មាប៉ូគាត់បំរុងទុកកន្លែងក្នុងរទេះសំរាប់ប្រពន្ធគាត់ ព្រមទាំងក្មេង ខ្លះៗដែរ ។ តែវាបង្អៀតពេក ខ្ញុំ សេននិងវ៉ាន់ឌីសុខចិត្តដើរតាមពីក្រោយរទេះ។

មកដល់ផ្សារឈើទាល នាងឈឿន នាងយេន ព្រមទាំងនាងណារី ក៏ចុះដើរដែរ ដោយសារនាងទាំងបី មិនចង់ឲ្យធូន់រទេះ ឬក៏ដោយសារតម្រិះប្រាជ្ញាផ្សេងៗ ។

ដោយសារ មានការហត់នឿយ ឬក៏ដោយសារ ចង់ពន្យារ ឲ្យបានវែងអន្លាយ ប្រយោជន៍នឹងបាន សប្បាយក្អាកក្អាយ ជាមួយនឹងស្រីៗ ខ្ញុំ និងសេន ក៏ណាត់គ្នា បន្ថយ ជំហាន ឲ្យរយាលឆ្ងាយពីរទេះ ដើម្បីនឹងសំណេះសំណាលគ្នា ឲ្យបានយូរ ប្តូរផ្តោះផ្តង អន្លូងស្នេហា ។

សេចក្តីស្នេហា រវាងខ្ញុំ នឹងនាងណារី បានប្រព្រឹត្តទៅ តែដោយសារ តែអក្ខរាសាស័ព្ទ រៀបរាប់ដោយពាក្យសម្តី គ្មានអ្វី ជាការសំខាន់ ដល់រាងកាយ ដៃ ប្រមុះថ្ពាល់...។

និយាយ មកដល់រឿងនេះ គួរឲ្យខ្ញុំខ្មាសអស់លោកអ្នកអាន ណាស់ ព្រោះខ្ញុំ ហាក់ដូចជាប្រុសមិនដុះកុយ ។

ចំប៉ាបាត់ដំបង បានអន្លង់ លួងប្រលេះបេះដូងខ្ញុំហើយ ក៏ធ្វើឲ្យវាស្វិតស្រពោន ទៅ !

ចុងឆ្នាំ១៩៥៩ ខ្ញុំត្រូវទៅប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សា នៅឯក្រុងភ្នំពេញ។ ខ្ញុំពុំស្គាល់ក្រុងភ្នំពេញសោះ ។ ជាភ័ព្វសំណាងល្អរបស់ខ្ញុំ ព្រោះគាប់ជួនពេលនោះបង គង់ទូចត្រូវទៅបំពេញវិជ្ជា ជានាយទាហាន ឯក្រុងភ្នំពេញដែរ។ កាលណោះគង់សេន រៀននៅថ្នាក់ទី៤ ហើយសេនក៏សុខចិត្តជូនខ្ញុំទៅប្រឡង ក្នុងគោលបំណង បានជួបឪពុកម្តាយ ហើយនិងជួយសម្រួលដល់ការលំបាករបស់ខ្ញុំផង ។

ទៅប្រឡងឌីប្លូម មានមិត្តម្នាក់ទៀត ឈ្មោះ ញ៉ឹកហោ ទៅជាមួយដែរ ។

យើងទាំងបីនាក់ បានធ្វើដំណើរ តាមរទេះភ្លើង ដោយយក កង់ម្នាក់មួយ ទៅផង សំរាប់ជាយានជំនិះ នៅក្រុងភ្នំពេញ ។

ដល់ភ្នំពេញខ្ញុំវង្វេងស៊ុងពុំស្គាល់ទិសដំបន់អ្វីសោះទេ ! កុំតែបានគង់សេនទៅ ជាមួយ ហើយជួយណែនាំផ្លូវ កុំអីខ្ញុំ ពុំដឹងជា ទៅរកសាលាព្រះស៊ីសុវត្ថិ ដែលជាកន្លែង ប្រឡងឃើញទេ !

គួរ ឲ្យនឹក អាណិត អាសូរ ដល់ខ្លួន ណាស់ ហេតុតែបាន យោនយក កំណើត កើតក្នុងត្រកូលអ្នកក្រក្រី កម្រនឹងបាន ទៅកាន់ទីដំបន់នានា ដែលនៅជុំវិញខ្លួន ជាពិសេសទីក្រុងនិងទីរួមខេត្តទាំងឡាយ នៅក្នុងប្រទេសខ្មែរ តែម្តង!

ខ្ញុំ ជិះកង់លើតែផ្លូវ ដដែលៗ ដែលខ្ញុំធ្លាប់ជិះ ។ ខ្ញុំស្គាល់ច្បាស់ តែផ្លូវព្រះបាទនរោត្តម ផ្លូវព្រះបាទមុនីវង្ស និងផ្លូវដែលត្រូវត្រឡប់ទៅមកផ្ទះ គឺផ្លូវស្របនិងវត្តព្រះពុទ្ធមានបុណ្យ ឆ្លងកាត់ផ្លូវធំមួយក្បែរផ្សារដីប៉ូ ។

ផ្ទះ ដែលខ្ញុំស្នាក់នៅ នៅត្រង់ម្តុំ ភូមិទឹកល្អក់ ចម្ងាយ ប្រហែល ២គីឡូម៉ែត្រ កន្លះ ពីសាលាព្រះបាទស៊ីសុវត្ថិ ។

ក្រោយប្រកាសលទ្ធផលនៃវិញ្ញាសាសរសេរ ខ្ញុំត្រូវមានឈ្មោះទៅប្រឡងវិញ្ញាសាសួរផ្ទាល់មាត់ទៀត ចំណែក មិត្តញ៉ឹកហោ គ្នាគ្មានវាសនា ដូចខ្ញុំទេ ។

ក្រោយពេល ញ៉ាំបាយល្ងាច ខ្ញុំក៏ស្ទុះទៅលើកកង់ យកមកទុកលើផ្ទះ ព្រោះខ្ញុំត្រូវប្រញាប់នឹងពិនិត្យ ផ្ទៀងផ្ទាត់ មេរៀន យ៉ាងច្រើនសន្ធឹកសន្ធាប់ សំរាប់ឆ្លើយដោះសារនៅថ្ងៃស្អែក ។

ញ៉ឹកហោដោយសារការពុំបានសំរេច ក៏ខកចិត្ត ហើយ រវល់តែ សាកប្ដា ជាមួយបងគង់ទូច ដែលកំពុងតែជួយលួងលោមនិងលើកទឹកចិត្ត ។

នៅពេលដែលញ៉ឹកហោ ចុះទៅយកកង់ ពុំដឹងជា ម៉ោងប៉ុន្មានទេ ព្រោះខ្ញុំកំពុងតែស្ងុងនៅក្នុងបន្ទប់ រំលឹក មេរៀន សាចុះសាឡើង ស្រាប់តែឮសម្រែកធោឡោ ថាចោរលួចកង់បាត់ ។

ខ្ញុំក៏ស្ទុះចុះមកជួយរកមើល ដោយសេចក្តីអាណិត មិត្តញ៉ឹកហោជាពន់ពេក ។ ណាមួយ គ្នាប្រឡងក៏ពុំជាប់ ហើយកង់ក៏ត្រូវចោរលួចទៅទៀត ។ ចុះហេតុអ្វី ក៏យ៉ាងដូច្នេះ ប្រាក់ក៏បង់ថង់ក៏ដាច ។

សព្វថ្ងៃ ញ៉ឹកហោ ក្លាយជាខ្មែរភៀសខ្លួន នៅរដ្ឋកាលីហ្វរនីញ៉ា នៃសហរដ្ឋអាមេរិក ។

ពេញមួយយប់នេះ ខ្ញុំឥតបានទទួលទានដំណេកទេ ដោយខំប្រឹងមើលមេរៀនឲ្យទាល់អស់ ហើយចេះតែពិចារណាថាមិនសមសោះ ចោរអីក៏សាហាវម៉េះ លួចប្លន់តែអ្នកកំសត់ដូចគ្នា!

ខ្ញុំបានប្រឡងជាប់ឌីប្លូមដោយបានទទួលពិន្ទុល្អបង្គួរ ។

ត្រឡប់មកដល់បាត់ដំបងវិញ ឪពុកម្ដាយ បងប្អូន មីងមាអ៊ំ ព្រមទាំងអ្នកដែលស្គាល់ខ្ញុំទាំងប៉ុន្មាន ជាពិសេស នាងឈរីទទួលអបអរសាទរនិងជូនពរឲ្យរឹតតែប្រសើរ ។

ពេលវ៉ាកង់ចូលមកដល់ ខ្ញុំ បាន សុំអនុញ្ញាត អំពីឪពុក ម្ដាយ ចិញ្ចឹមរបស់ខ្ញុំ ដើម្បីទៅរករៀន នៅឯភ្នំពេញ ព្រោះមានគ្រូបារាំងល្បីៗ បើកបង្រៀនវិជ្ជាចំណោទដល់សិស្សណាដែលអាចបង់ថ្លៃឈ្នួល ។ ការដែលខ្ញុំប្រថុយមកសំណាក់នៅភ្នំពេញ ក្នុងរយៈពេលវ៉ាកង់នេះ ដោយសារខ្ញុំមានស្គាល់មិត្តម្នាក់ឈ្មោះតឹកមាង់ ដែលអួតអាងនិងសន្យានិងខ្ញុំថា គេនឹងធានាគ្រប់បែបយ៉ាង ខាងរកផ្ទះនៅ និងសេចក្ដីត្រូវការផ្សេងៗ ។

ឪពុកម្ដាយខ្ញុំ បានឲ្យប្រាក់ចំនួន១៧០០រៀល ។ ៦០០រៀល សំរាប់ បង់ថ្លៃសាលា ៦០០រៀល សំរាប់ចាយវាយក្នុងរយៈពេល២ខែ ៣០០រៀល សំរាប់ទិញសៀវភៅមើល និងប្រដាប់ប្រដារផ្សេងៗ ២០០រៀលសំរាប់បង្ការទុកក្នុងការធ្វើដំណើរ និងការប្រើប្រាស់ផ្សេងៗ ។

ដល់ភ្នំពេញតឹកមាង់ បាននាំឲ្យខ្ញុំស្គាល់ មិត្តម្នាក់ ឈ្មោះច្រាក់សារ៉ុត ។ សារ៉ុត ជាក្មេងកម្លោះមានសុខភាព ស្អកស្ដម្ភ កម្លាំងពលំមាំមួនជាអ្នកចូលចិត្តកីឡា រក្សាសុខភាពនិងសាច់ដុំ ។ នាយមានសម្បុរខ្មៅស្រស់ ។ នាយទទួលខ្ញុំដោយរាក់ទាក់ ព្រមទាំងឲ្យខ្ញុំ សំណាក់នៅផ្ទះវាផង បើខ្ញុំមានបំណងបង់បន្តការសិក្សា ដោយសារផ្ទះនោះ ឥតមានអ្នកណានៅក្រៅពីវា ព្រោះថាឪពុកម្ដាយវា រស់នៅឯខេត្ត ។ ផ្ទះនោះ តាំងនៅក្នុងភូមិទួលស្វាយព្រៃ ។ ខ្ញុំទើបនឹងបាន យល់ ពីការអួតអាងរបស់ តឹកមាង់ ដែលវាថាធានាគ្រប់បែបយ៉ាង ព្រោះ វាអាងទៅលើសារ៉ុត តាមពិតវាក៏មានជីវភាពលំបាកដែរ ។ ម្ដាយវាជាស្រីមេម៉ាយ រស់នៅស្រុកត្រាំកក់ ខេត្តតាកែវ មានកូនប្រុសបីនាក់ ។ បងប្រុសទី១ ឈ្មោះតឹកវ៉ាន់ថា ធ្វើគ្រូបង្រៀន នៅស្រុកបវិល ខេត្តបាត់ដំបង បងប្រុសទី២ ឈ្មោះ

តឹកម៉ានី ជាសិស្សភ្នាក់ងារកសិកម្ម នៅព្រែកលៀបជាមួយគៀងចំក់ ។ ខ្ញុំស្គាល់តឹកម៉ានី និងតឹកមាច់ ដោយសារសំឡាញ់គៀងចំក់នេះឯង ។

ដោយយល់ថា ការសិក្សារបស់ខ្ញុំនាំឲ្យមានការរំខានដល់គេឯង ខ្ញុំក៏សំរេចក្នុងចិត្តថាត្រូវតែបោះបង់ការចង់រៀនឈ្នួលចេញ ព្រោះខ្ញុំមិនទាន់ត្រូវការជាចាំបាច់ណាស់ណាទេ ខ្ញុំនៅសល់ពេលមួយឆ្នាំទៀត គឺចាំដល់ខ្ញុំបញ្ចប់ការសិក្សានៅថ្នាក់ទី២សិន សឹមបន្តរៀនឈ្នួលទៅ ក៏មិនហួសពេលដែរ ។ គិតដូច្នោះ ហើយខ្ញុំក៏យកលុយទៅទិញសៀវភៅ និងរបស់របរផ្សេងៗ អស់៦០០រៀល នៅសល់តែ១១០០រៀល ។

ខ្ញុំគ្រោងទុកថា ថ្ងៃស្អែក ខ្ញុំនឹងវិលត្រឡប់ទៅបាត់ដំបងវិញហើយ ។

ទទួលខ្ញុំ ហើយនិងតឹកមាច់ ជិះកង់ម្នាក់មួយ កាត់ភូមិអារ៉ាប់ ស្រាប់តែជួប និងសំឡាញ់គៀងគោក ទាំងសាប់ទាំងឈាម តែម្តង ។

គោក សួរខ្ញុំថា ឯងមកពីណា ហើយទៅណាដូចជារហាក់រហន់ម៉្លេះ?

ខ្ញុំឆ្លើយថា គ្នាមកពីទួលស្វាយព្រៃ ហើយប្រញាប់ទៅផ្សារថ្មី ដើម្បីទៅរកទិញសំបុត្រឡានត្រឡប់ទៅបាត់ដំបងវិញ នៅថ្ងៃស្អែក ។

គោកហៅយើងទាំងពីរនាក់ ចូលលេងក្នុងផ្ទះវា ដែលទើបតែនឹងជួលបាន ពីម្សិលមិញ ។

យើងចូលក្នុងផ្ទះតាមសំណើ ។ ផ្ទះនោះមានពីរបន្ទប់ ។ គោកជួលមួយបន្ទប់ សល់ទំនេរមួយបន្ទប់ ។

ខ្ញុំនឹកឆ្ងល់ក្នុងចិត្ត ថាហេតុអ្វីក៏វាមកជួលផ្ទះនៅទីនេះ ។ តែខ្ញុំមិនហ៊ានសួររឿងហេតុទេ ។

ក្រោយពីការសំណេះសំណាល ជាងកន្លះម៉ោងមក គោកវាឃាត់ខ្ញុំ កុំឲ្យទៅណា ហើយវាបបួលខ្ញុំឲ្យសំណាក់នៅជាមួយវា ក្នុងពេលវ៉ាកង់នេះ ព្រោះវាមករករៀនឈ្នួល ។ ឮដូច្នោះ ខ្ញុំក៏ចង់នៅជាមួយវាដែរ តែខ្ញុំបានផ្តាច់ចិត្តរួចហើយ ថានឹងត្រឡប់ទៅផ្ទះវិញ ដោយបានចំណាយលុយទិញរបស់របរអស់មួយចំនួនហើយ ។

គោកវានៅតែទទូចសុំឲ្យខ្ញុំនៅជាមួយវា ដោយវាធានាថា ចំពោះបាយទឹក កុំឲ្យខ្ញុំព្រួយ ព្រោះវាបានគ្រោងទុកអង្ករមួយបាវ ទម្ងន់១០០គីឡូ ទោះស៊ី៣ខែក៏មិន

អស់ដែរ  ចំណែកម្ហូប ក៏វាមានត្រីងៀត ត្រីឆ្អើរ ប្រហុក អំបិល  ទឹកត្រី ទឹកស៊ីអ៊ីវ  គ្រប់សព្វហើយ  ហើយថ្លៃផ្ទះ វាបង់រួចហើយ  មិនថ្លៃទេ ។ បន្ទប់មួយនេះ អាចនៅបានពីរនាក់ដោយ យើង ជាកូនសិស្ស ពុំមាន របស់ អ្វី ច្រើន ទេ  ក្រៅ ពី កូន ហិប មួយ សំរាប់ដាក់ខោអាវ និងសៀវភៅរៀន។

ខ្ញុំ ក៏ដាច់ចិត្ត  ស្នាក់នៅជាមួយតោក  ម្យ៉ាងដោយខ្ញុំចង់រៀនឈ្នួល ម្យ៉ាងទៀតដោយខ្ញុំខានជួប វាយូរហើយ ។

ថ្ងៃក្រោយ  តឹកហង់ក៏មកជួល បន្ទប់ទំនេរ ។

នៅ ភូមិអារ៉ាប់  ខ្ញុំ ឃើញទាន់ ជាញឹកញាប់  តោក វាទាក់ទងស្នេហា នឹង ក្រមុំចិន លក់ទឹកកក  នៅក្បែរផ្ទះ  តែថ្ងៃក្រោយ  កញ្ញាសូឡិបខ្មៅ  តាមមកទាន់ ក៏នាងពុំព្រមបណ្ដែតបណ្ដោយឲ្យតោក មានសេរីភាពតទៅទៀតទេ។ កាលណោះ នាងត្រូវរៀនបំពេញវិជ្ជា ខាងពេទ្យធ្មេញ  នៅឯភ្នំពេញដែរ នាងតែងតែ មកមើលថែ ទាំដំនឹងស្នេហារបស់តោកជានិច្ច ។

សេចក្ដីស្នេហារវាងតោក និង នាងកញ្ញាសូឡិបខ្មៅ  ក៏ល្អូកល្អឺន នឹងគ្នា លុះត្រាឥឡូវ  រហូតត្រូវខាំបេករបួត ខាំពោតរបេះ ខ្នាំងបាញ់ជំរេះ  មិនអាចបង្វេះបង្វែងបាន!

ឆ្នាំ១៩៥៩-៦០ខ្ញុំ រៀននៅថ្នាក់ទី២។ ដាច់ឆ្នាំខ្ញុំត្រូវបានឡើងថ្នាក់ទី១ ជាស្ថាពរ ។

ក្នុងឆ្នាំនេះ គង់សេន ត្រូវបែកពីនាងយ៉េន  ព្រោះឪពុក ម្ដាយរបស់ នាង  បាន បង្ខំឲ្យនាង រៀបការ  នឹង  បង ប្អូន ជីដូន មួយ ឈ្មោះផុន ដែលទើបតែ ប្រឡងជាប់ របរ រកស៊ីធ្វើគ្រូបង្រៀន  ជានាម៉ឺនជីស ។

គង់សេន មានវិបត្តិស្នេហា  ក្នុងពេលជាមួយ ដែលត្រូវ ប្រឡង យកសញ្ញាប័ត្រ ឌិប្លូមផង ។ លទ្ធផលនៃការប្រឡង រឹតតែធ្វើឲ្យគង់សេន លំបាកចិត្តជាទ្វេ ។ គង់សេនត្រូវ បង្ខំចិត្ត ចូលរៀន នៅសាលាឈ្នួល ។

ខែ៦ឆ្នាំ១៩៦១ខ្ញុំត្រូវទៅប្រឡងបាក់ទី១នៅភ្នំពេញ  គង់សេន ក៏សុខចិត្តទៅតាមជួយ រកកន្លែងស្នាក់នៅជូលខ្ញុំ ព្រោះវាស្គាល់ គុនស៊ុន ថៅកែតុយទាវ កាហ្វេ ដែលត្រូវជាក្មួយ របស់ បងគង់ទួច ។

ប្រឡងបាក់ទី១ នៅលើកទី១នេះ  ខ្ញុំពុំបានទទួលលទ្ធផលល្អទេ ។

បំណែកគង់សេន វាមាន លាភសត្វជើងពីរ ។ ជាផ្កាត្របែកព្រៃ នាងមានឈ្មោះ ទ៉ាន់ថា ជាកូនចៅហ្វាយស្រុក កំពង់ត្របែក ដែលមកស្នាក់នៅផ្ទះម្តាយមីង ឯនៅភ្នំពេញ ដើម្បីការសិក្សាអប់រំខ្លួន ។

គង់សេន វាមាន ទេពកោសល្យណាស់ ក្នុងរឿងទាក់ចិត្តសិស្សនារី ។ រូបវាសង្ហារ ក៏ពិត តែវាមានល្បិចច្រើន ។ វាប្រាប់ខ្ញុំថា វាឃើញនាងទ៉ាន់ថា ចូលទៅទិញអីវ៉ាន់ ក្នុងតូបមួយ ។ ដោយបានឃើញផ្កាត្របែកព្រៃមានសម្រស់ សម្រើបជាងផ្កាឫស្សីក្រោកទៅទៀត គង់សេន ក៏ក្តួបចិត្តមូលគំនិតថា “ បើសេះដាច់ត្រូវតែយកសេះតាម ឬថា បើបន្លាមុត ត្រូវតែយកបន្លាមកដស់ ” ។ គិតយ៉ាងដូច្នោះ វាក៏ឆ្លៀត ឱកាសល្អ យកជើងជាន់ ជើងនាងវ៉ាន់ថា ដោយបន្ទើរ ល្មមឲ្យតែនាងដឹងខ្លួន ហើយវានឹងអាលសុំទោសនាងជាខាងក្រោយ ដោយមានគោលបំណង ល្បងនាងឲ្យចូលក្នុងអន្ទាក់ស្នេហា ។ ចាប់តាំងពីថ្ងៃនោះមក វាក៏មានភ័ព្វវាសនា ទទួលនាងទ៉ាន់ថា ជាគូកំណាន់ចិត្ត បិទរបួសស្នាមស្នេហាចាស់ ។

វិលមកដល់បាត់ដំបងវិញ ខ្ញុំប្រឹងខិតខំរៀន ជាមួយក្រុំសិស្ស មានគ្នាបួននាក់គឺ គុយជិនហាន់ កង សារីវ៉ាត់ ឌុនសាវ៉ាន់ និងខ្ញុំ ។

ក្នុងចំនួនសិស្ស ទាំងបួននាក់ មានតែគុយជិនហាន់ទេ ដែលបានប្រឡងធ្លាក់ ។ នៅលើកទី២ នេះ ខ្ញុំបានទទួលលទ្ធផលជាទីគាប់ចិត្ត គឺបានពិន្ទុ លេខល្អបង់គួរ ។

សព្វថ្ងៃ ឌុនសាវ៉ាន់ រស់នៅឯសហរដ្ឋអាមេរិក កងសារីវ៉ាត់ នៅប្រទេសកាណាដា បំណែកឯគុយជិនហាន់ពុំដឹងជានៅឯណាទេ ។ និយាយមកដល់ត្រឹមនេះ គួរឲ្យខ្ញុំនឹករលឹក ទៅដល់មិត្តសំឡាញ់ ទាំងបីនេះជាពន់ពេក ។ តើនៅថ្ងៃណា នឹងបានជួបជុំគ្នាដូចសព្វមួយដង គ្រាន់នឹងបានសាសងគ្នា ឲ្យបានបែកពពុះមាត់ខ្ចាយផ្សាយជាអូរ ហូរជាស្ទឹង?

សេចក្តីស្នេហា រវាងខ្ញុំ និង បំប៉ាបាត់ដំបង បានកន្លងអស់រយៈពេលជាង៣ឆ្នាំ គឺ ចាប់តាំងពី ចុងឆ្នាំ១៩៥៨ រហូតដល់ខែ៦ ឆ្នាំ១៩៦២ ដែលជាថ្ងៃ ដែលខ្ញុំត្រូវប្រឡងធ្លាក់ បក្កវិញ្ញាបត្រ ថ្នាក់ទី២ ( Baccalauréat 2ème partie )

*ក្រោយថ្ងៃប្រឡងថ្នាក់ បក្កវិញ្ញាប័ត្រ ថ្នាក់ទី២ (ធ្លាក់ឌុប) ទើបខ្ញុំផ្តាច់ចិត្ត លែងស្រលាញ់ស្បូវសង្សារបោល ទុកឲ្យនាងតែលតោល ត្រមង់ត្រមោច កណ្តាប កណ្តែងពុំយល់ និងពុំដឹងហេតុផល! ចំណែកខ្លួនខ្ញុំ ពុំយល់ពីហេតុនេះ ដែលនាំឲ្យខ្ញុំទៅដាច់ចិត្តយ៉ាងនេះដែរ!*

ប្រាកដជាមិនមែនគូព្រេងខ្ញុំទេ នេះគឺជាស្រមោលគូកម្ម ប្រចាំសព្វប្រាណ!

—ចប់ភាគ៣—